សម្លេងខ្មែរនៅបរទេស

# តើនរណាធ្វើឱ្យខ្មែរបាត់បង់ទឹកដី?

ដោយ លី-ឌៀប ★ ថ្ងៃទី១ មិថុនា ២០០៤

បើស្ដាប់តាមការផ្សាយទូរទស្សន៍ខ្មែរទីក្រុងឡុងប៊ីច (CAM-TV) កាលពីថ្ងៃសៅរ៍ទី២៩ឧសភា២០០៤ ក្នុងឱកាសលៀងភោជនាហារជាកិត្តិយសចំពោះទ្រង់រណប្ញទ្ធិ ប្រធានគណបក្សហ៊្វុនស៊ិនប៉ិច យើងបានស្ដាប់ព្ទទ្រង់រណប្ញទ្ធិថ្លែងអំពីមេដឹកនាំ និងបូរណភាពទឹកដីខ្មែរដូច្នេះថា ៖ « ព្រះមហាក្សត្រខ្មែរ ទោះបីខ្សែនរោត្តមក៏ដូចជាខ្សែស៊ីសុវត្ថិ និងខ្សែផ្សេងៗទៀតដែរ តែងស្រឡាញ់ប្រទេសជាតិនិងខំការពារទឹកដីមិនឲ្យបាត់បង់ទេ ពីព្រោះយើងដឹងថាជាសាសន៍ខ្មែរពិតប្រាកដ ។ តែបើខ្មែរជ្រើសរើសមេដឹកនាំថ្មី ជួនកាលមិនបានដឹងថាជាជាតិសាសន៍បរទេស នោះខ្មែរអាចបាត់បង់ឯករាជភាពនិងបូរណភាពទឹកដីរបស់ខ្លួន» (sic) ។

សំដីរបស់ទ្រង់រណប្ញទ្ធិនេះចង់មានន័យថា ៖ ស្ដេចពុំដែលបានធ្វើឲ្យបាត់បង់ទឹកដីនគរទេ គឺមានតែ<រាស្ត្រ> ឬមេដឹកនាំខ្មែរណាដែលគេមិនដឹងថាជាជាតិសាសន៍បរទេសប៉ុណ្ណោះ អាចធ្វើឲ្យខ្មែរបាត់បង់ឯករាជភាពនិងទឹកដី ។ សំដីនេះធ្វើឲ្យយើងចាប់អារម្មណ៍យ៉ាងខ្លាំង ហើយយកមកពិចារណាត្រិះរិះដណ្ដឹងសួរខ្លួនឯងថា ៖ តើទ្រង់រណប្ញទ្ធិចង់បន្ទោសការបាត់បង់ទឹកសព្វថ្ងៃនេះ លើមេដឹកនាំខ្មែរណាមួយ ដែលមាន<ឋាន:> ជារាស្ត្រប្រជា ហើយដែលគេមិនដឹងថាជាជាតិសាសន៍បរទេសនោះ ?? តើជាលោកលន់-នល់, ខៀវ-សំផន, ចាន់-ស៊ី, ប៉ែន-សុវណ្ណ, ហេង-សំរិន ឬមួយក៏ហ៊ុន-សែន (??) ។

ដើម្បីយល់ដឹងគ្រួសៗអំពីបញ្ហានេះ យើងសាកល្បងធ្វើវិភាគដូចតទៅ ៖

★ នរោត្តម-សីហនុ ៖ យើងធ្លាប់បានឮតាមប្រវត្តិសាស្ត្របូរហែមកថា ស្ដេចជ័យជេដ្ឋាទី២ ដោយមានការអង្វរករសុំខ្ទីដីពីប្រពន្ធយួនរបស់ទ្រង់ ដើម្បីចែកឲ្យជនជាតិយួនរស់នៅផង បានប្រគល់ទឹកដីខេត្តកំពង់ក្របី ព្រៃនគរ ទៅឲ្យយួន ។ យើងឮថា ស្ដេចចោលម្ជៀតអង្គនេះគ្រាន់តែឲ្យ«ខ្ទី»ប៉ុណ្ណោះ និងពុំបានឮថា«ប្រគល់ទៅយួន»ទាំងស្រុងនោះទេ ។ តែដែលយើងបានដឹងពិតប្រាកដវិញ គឺនៅឆ្នាំ១៩៤៩ (ក្រោមរាជ្យរបស់ព្រះបាទនរោត្តម-សីហនុ) ទឹកដីកម្ពុជាក្រោមទាំងមូល បានធ្លាក់ទៅក្នុងកណ្ដាប់ដៃយួនជា «ផ្លូវការ» ។ ការបាត់បង់ទឹកដីខ្មែរនេះ មិនមែនមួយចំអាមពីរចំអាម, មិនមែនមួយម៉ែត្រឬពីរម៉ែត្រ, មិនមែនមួយគីឡូឬពីរគីឡូនោះទេ... គឺទឹកដីរាប់ខេត្តខ័ណ្ឌតែម្ដង (!!) ។ មកដល់អំឡុងទសវត្សឆ្នាំ៦០ទៀត, មានឯកសារប្រវត្តិសាស្ត្រជាច្រើនបញ្ជាក់ថា ស្ដេចឈ្មោះនរោត្តម-សីហនុដដែលនេះ បានអនុញ្ញាតឲ្យពួកយួនយៀកកុង-យៀកណាមខាងជើង ចូលមកតាំងមូលដ្ឋានទ័ព នៅក្នុងទឹកដីខ្មែរតាមបណ្ដោយព្រំដែនទិសខាងកើត ។ បន្ថែមពីលើនេះទៀត នរោត្តម-សីហនុបានជួយសំរួលការដឹកជញ្ជូនស្បៀង មានគ្រាប់រំសេវ ថ្នាំពេទ្យ ឧបករណ៍ប្រើប្រាស់ ម្ហូបអាហារ ទៅឲ្យពួក<បូដូយ>ទាំងអស់នេះថែមទៀត ។ គេដឹងថា គឺមកពី<កំហុសក្បត់ជាតិខ្មែរ>នេះឯងហើយ ទើបប្រជាពលរដ្ឋខ្មែរសំរេចចិត្តនាំគ្នាដង្ហែរនរោត្តម-សីហនុ ហួសពីតំណែង<ប្រមុខរដ្ឋ>តែម្ដងទៅ ។ កំហុសដ៏ធ្ងន់ធ្ងរជាទីបំផុតរបស់នរោត្តម-សីហនុ គឺព្រះអង្គបានធ្វើការសងសឹកចំពោះរបបសាធារណរដ្ឋខ្មែរ ដោយហក់ទៅចូលដៃជាមួយពួកខ្មាំងសួរជាតិ ហើយគៀងគរពន្យុះពួកនេះ ឲ្យហក់ចូលមកសម្លាប់ប្រជាពលរដ្ឋខ្លួនឯង និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិខ្មែរ ស្ទើរពាយអស់មួយនគរ ។ ជាមួយការជ្រោមជ្រែងនៃពួកយៀកកុង-យៀកណាមខាងជើងនេះហើយ ទើបពួកខ្មែរក្រហមបានទទួលជោគជ័យលើរបបសាធារណរដ្ឋខ្មែរ ដោយបានលើកនរោត្តម-សីហនុឡើងធ្វើជា «ប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យ» ដែលជារបបប្រល័យពូជសាសន៍ខ្មែរអស់ជិត៣លាននាក់ និងធ្វើឲ្យស្រុកខ្មែរប្រែក្លាយទៅជា <ស្រុកខ្មោច> ។

★ លន់-នល់ ៖ គឺជាមេដឹកនាំខ្មែរម្នាក់ទទួលថ្នបាក់ពីស្ដេចសីហនុ។ ព្រឹត្តិការណ៍១៨មិនា១៩៧០កើតឡើង គឺគ្មានអ្វីក្រៅអំពីរឿង«បណ្ដេញកងទ័ពយៀកកុង-យៀកណាមខាងជើង» ចេញពីទឹកដីខ្មែរនោះឡើយ ។ របបសាធារណរដ្ឋខ្មែរ បានបូជាអាយុជីវិតយុទ្ធជននិងប្រជាពលរដ្ឋជាច្រើនណាស់ ដើម្បីការពារបូរណភាពទឹកដី ពីការឈ្លានពានរបស់យួននេះ ។ បើកាលណោះនរោត្តម-សីហនុសុខចិត្តនៅស្ងៀម (ដូចស្ដេចបៅដាយ) មិនហក់ទៅនៅខាងខ្មាំងទេ ស្រុកយើងពិតជាមិនបានជួបប្រទះនូវវិនាសកម្មដូចសព្វថ្ងៃនេះដែរ ។ ទឹកដីក៏នៅគង់វង់ ហើយឈាមខ្មែរក៏ពុំបានហូរដាបពោះដីរយ៉ាងដូច្នេះឡើយ ។ របបសាធារណរដ្ឋខ្មែរ ពុំបានអនុញ្ញាតឲ្យជីដល់ពួកយៀកកុង-យៀកណាមខាង ជើងតាំងមូលដ្ឋានទ័ព ហើយពុំបានធ្វើសន្ធិសញ្ញាបែងចែកទឹកដីអ្វីជាមួយប្រទេសជិតខាងណាមួយទេ ។ បរាជ័យនៃរបបសាធារណរដ្ឋខ្មែរ គឺពុំអាចទប់ទល់នឹងសត្រូវយួនដ៏ធំ និងដ៏មានកម្លាំងខ្លាំងក្លា ដែលមាននរោត្តម-សីហនុជាអ្នកពន្យុះពីក្រោយនោះយ៉ាងពិតប្រាកដណាស់ ។ ដូច្នេះ, តើនរណាទៅជាអ្នកគាំពារសត្រូវឈ្លានពានទឹកដីខ្មែរ (??) ។ គឺពុំមែនជា «ឪពុក» របស់នរោត្តម-រណប្ញទ្ធិទេឬ (??)...

★ ខៀវ-សំផន ៖ ប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យទី២នេះ ក៏ពុំបានបែងចែកទឹកដីខ្មែរទៅឲ្យយួនដែរ ថ្វីបើត្រូវចាញ់កលយួនក្នុងអំពើវាយប្រហារដណ្ដើមយកទឹកដីកម្ពុជាក្រោមមកវិញក៏ដោយ ។ ការប្រព្រឹត្តអំពើសម្លាប់រង្គាលមកលើជនជាតិខ្លួនឯង គឺជាការទទួលខុសត្រូវនៃប្រមុខរដ្ឋរូបនេះ ព្រមទាំងថ្នាក់ដឹកនាំទាំងអស់នៃរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំងនរោត្តម-សីហនុនៅក្នុងនោះផងដែរ ។

★ ពួកមេដឹកនាំជាអាយ៉ងយួន ៖ ពាក្យហៅថា «អាយ៉ងយួន» វាមានន័យគ្រប់គ្រាន់ណាស់ទៅហើយ ដោយពុំចាំបាច់បញ្ជាក់ប្រាប់ថា ពួកអស់នេះសុខចិត្តបែងចែកទឹកដីខ្មែរ ទៅឲ្យចៅហ្វាយយួនរបស់ខ្លួននោះទេ ។ សន្ធិសញ្ញាព្រំដែនខ្មែរ-យួនឆ្នាំ១៩៧៩, ១៩៨២, ១៩៨៣ និង១៩៨៥ គឺខាងយួន«ត្រូវតែឆ្លៀតឱកាសធ្វើ» នៅក្រោមការឈ្លានពានរបស់ខ្លួនចាប់ពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៨៩ (១ទសវត្ស) យ៉ាងពិតប្រាកដណាស់ ។ ពួកខ្មែរយៀកមិញទាំងអស់នេះ មិនខុសគ្នាពីនរោត្តម-សីហនុឡើយ គឺបានទៅគៀងកងទ័ពយួន ចូលមក«ឈ្លានពាន»ស្រុកខ្មែរ ។ ការកំចាត់ពួកខ្មែរក្រហមចេញពីអំណាច វាគ្រាន់តែជាការ «ផ្លាស់ប្ដូរអាយ៉ង» របស់ខ្លួន ពីក្រុមចាស់មកក្រុមថ្មីមួយទៀតប៉ុណ្ណោះ (!!) ។ តើទង្វើរបស់នរោត្តម សីហនុកាលពីឆ្នាំ១៩៧០ និងទង្វើរបស់ពួកខ្មែរយៀកមិញក្នុងឆ្នាំ១៩៧៩ ខុសគ្នាអ្វីទៅ (??) ។ មានន័យថា ជនជាអ្នកហុចដងដាវទៅឲ្យសត្រូវរបជាតិខ្មែរ គឺគ្មាននរណាក្រៅអំពីនរោត្តម-សីហនុនិងពួកខ្មែរយៀកមិញទាំងអស់នេះទេ ។ ទឹកដីខ្មែរត្រូវគេឈ្លានពានឬត្រូវរបេះ គឺដោយសារមក

ពីជនចង្រៃទាំងអស់នេះ (!!) ។

★ នរោត្តម-ចក្រពង្ស ៖ មេដឹកនាំ<ការបំបែកទឹកដីខ្មែរ>ទៅយួននៅក្រោយពេលបោះឆ្នោត<អ៊ុនតាក់>ឆ្នាំ១៩៩៣ ។ ជននេះត្រូវជាប្អូនប្រុសម្ដាយទីទៃរបស់នរោត្តម-រណឫទ្ធិ និងត្រូវជាកូនប្រុសរបស់នរោត្តម-សីហនុ ។ បើយើងមិនច្រឡំទេ នរោត្តម-ចក្រពង្ស មានឈាមជ័រជាស្ដេចក្នុងខ្សែ <នរោត្តម> ។ អំពើបំបែកទឹកដីខ្មែរយកទៅចូលយួនបែបនេះ មិនដឹងទ្រង់រណឫទ្ធិហៅថាជាស្អីទេ តែចំពោះយើងវិញដែលជារាស្ត្រសាមញ្ញហៅថា «ក្បត់ជាតិ» ។ នាពេលថ្មីៗនេះ គណបក្ស<ចក្រពង្សព្រលឹងខ្មែរ> បានថែមទាំងមកចុះចូលជាមួយគណបក្ស <ហ្វ៊ុនស៊ិនប៉ិច> ហើយនិងបានរួមសហការគ្នាជាមួយគណបក្ស<សម-រង្ស៊ី>ថែមទៀតផង ។

★ នរោត្តម-រណឫទ្ធិ ៖ រដ្ឋមន្ត្រីទី១-ទី១ (អាណត្តិឆ្នាំ១៩៩៣-១៩៩៨) និងជាប្រធានគណបក្សហ្វ៊ុនស៊ិនប៉ិច (ដៃគូនៅក្នុងរដ្ឋាភិបាលចំរុះឆ្នាំ១៩៩៣-២០០៣) ព្រមទាំងជាប្រធានសភាជាតិ (អាណត្តិទី២) ។ នៅក្នុងឋានៈខ្លួនជារដ្ឋមន្ត្រីទី១-ទី១ និងជាប្រធានសភាជាតិ, នរោត្តម-រណឫទ្ធិ ពុំបានប្រកាសលប់ចោលជា «មោឃៈ» សន្ធិសញ្ញាព្រំដែនខ្មែរ-យួនឆ្នាំ១៩៧៩-១៩៨២-១៩៨៣ និង១៩៨៥ ដោយអនុលោមទៅតាមកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ និងតាមរដ្ឋធម្មញ្ញឆ្នាំ១៩៩៣ទេ ។ មិនត្រឹមតែប៉ុណ្ណឹងសោត នៅក្នុងដំណើរទស្សនកិច្ចស្រុកយួនពីរលើក (ឆ្នាំ១៩៩៣ និង១៩៩៥) នរោត្តម-រណឫទ្ធិ ថែមទាំង «គាំទ្រ» សុពលភាពនៃសន្ធិសញ្ញាទាំងអស់នោះថែមទៀត ។ ទង្វើនេះគឺគ្មានអ្វីក្រៅអំពី«ឃុបឃិត»រួមចំណែកនៅក្នុងការបាត់បង់ទឹកដីខ្មែរនោះឡើយ ។

★★★ ដូច្នេះសរុបសេចក្ដីទៅ, រាស្ត្រខ្មែរសាមញ្ញ (ខ្មែរកម្ពុជាក្រោមក៏ដូចខ្មែរកណ្ដាលដែរ) គ្មាននរណាបានធ្វើឲ្យបាត់បង់ទឹកដី ទៅបរទេសជិតខាងទេ ។ គេឃើញតែ «ពួកស្ដេច» និងពួកកូនចៅស្ដេច ព្រមទាំងពួកកូនចិញ្ចឹមស្ដេចប៉ុណ្ណោះ ដែលជាពួកធ្វើឲ្យខ្មែរបាត់បង់ទឹកដី ។

យើងគ្មានសេចក្ដីសង្ឃឹមទាល់តែសោះថា ពួកអស់នេះនឹងសុខចិត្តលុបចោល<សន្ធិសញ្ញាព្រំដែនខ្មែរ-យួន> ដែលជាចំណុចក្ដៅមួយនៃកម្មវិធីនយោបាយបច្ចុប្បន្នឡើយ ។ ការពន្យា ហើយនិងការបង្កើត«ក្រុមប្រឹក្សាជាន់ខ្ពស់ទទួលបន្ទុកព្រំដែន» វាគ្មានអ្វីក្រៅអំពីជា «ការបោកប្រាស់» និងជា«ការបំភ័ន្ត» មតិប្រជាពលរដ្ឋខ្មែរតែប៉ុណ្ណោះ (!!) ៕